**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣៣✱៤៤៤

សម្ព័ន្ធចាប់ដៃ
CHAB DAI COALITION

លេខៈ ៩៩៧០.....សចដ

| | |
|---|---|
| ក្រសួងលេខាធិការដ្ឋាន គ.ជ.ប.ជ | |
| ចូល | លេខ: ១៩០/២៣ |
| | ថ្ងៃទី ២៤ ខែ ៨ ឆ្នាំ២០២៣ |
| | ម៉ោងចូលពី ៨:៤៥ |

**សូមគោរពជូន**

**លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍**

**គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)**

**កម្មវត្ថុ៖** សំណើសុំអនុញ្ញាតអញ្ជើញ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចូលរួមធ្វើបទបង្ហាញ ស្តីពី "ផែនការយុទ្ធសាស្ត្រ និងដំណោះស្រាយរបស់ គ.ជ.ប.ជ ដើម្បីឆ្លើយតបចំពោះការជួញដូរមនុស្សនៅកម្ពុជា" ក្នុងសន្និបាតប្រចាំឆ្នាំនៃអង្គការសម្ព័ន្ធចាប់ដៃលើកទី៣៧ នៅរាជធានីភ្នំពេញ។

សេចក្តីដូចគោរពជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមជម្រាប **លោកជំទាវ** មេត្តាជ្រាបថា **អង្គការសម្ព័ន្ធចាប់ដៃ** ជាអង្គការមិនមែនរដ្ឋាភិបាលបរទេស ធ្វើការលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ច និងទម្រង់ផ្សេងទៀតនៃការរំលោភបំពាន នឹងរៀបចំសន្និបាតប្រចាំឆ្នាំនៃអង្គការសម្ព័ន្ធចាប់ដៃលើកទី៣៧ ចូលរួមដោយផ្ទាល់ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃព្រហស្បតិ៍ **១៤រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣** ដែលនឹងមានអ្នកចូលរួមចំនួនប្រហែល ១០០ ទៅ ២០០នាក់ ជាមន្ត្រីនៃអង្គការសមាជិក និងដៃគូរបស់អង្គការសម្ព័ន្ធចាប់ដៃ។

**ពេលវេលា៖** ម៉ោង១០:០០នាទីព្រឹក ដល់១១:៣០នាទីព្រឹក ដែលមានរយៈពេល ១ម៉ោង និង៣០នាទី

**ទីកន្លែង ៖** ឌីខេ មីតធីងសេនធ័រ

**អាសយដ្ឋាន៖** ផ្ទះលេខ១៩ ផ្លូវ៣៣០ ភូមិ៦ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ

**ប្រធានបទ៖** "ផែនការយុទ្ធសាស្ត្រ និង ដំណោះស្រាយរបស់ គ.ជ.ប.ជ ដើម្បីឆ្លើយតបចំពោះការជួញដូរមនុស្សនៅកម្ពុជា"

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **លោកជំទាវ** មេត្តាចូលរួមជាវាគ្មិនក្នុងសន្និបាតខាងលើដោយសេចក្តីអនុគ្រោះ ។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីខ្ញុំបាទ។

ជូនចំពោះ/លេខា៣
ផ្តល់ [illegible] ២៤/សីហា/23

ថ្ងៃពុធ ១៥រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៣

**នាយកប្រចាំប្រទេស**

CHAB DAI COALITION

**Kneath Heard**

**ភ្ជាប់ជាមួយ៖**

- របៀបវារៈសន្និបាតប្រចាំឆ្នាំនៃអង្គការសម្ព័ន្ធចាប់ដៃ
- លេខទំនាក់ទំនង៖ (+៨៥៥)១២ ៦៧២ ៥៧៥
(+៨៥៥)៨៥ ៧៨១ ៨៣៨


យើងចង់ឃើញពិភពលោកមួយដែលសហគមន៍រស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ សុខដុមមេត្រា និងសេរីភាព

អាសយដ្ឋាន៖ ផ្ទះលេខ១៦៣ ផ្លូវលេខ២៧បេតេ សង្កាត់បឹងទំពន់ ខណ្ឌមានជ័យ ភ្នំពេញ ប្រអប់សំបុត្រលេខ១០១០

ទូរស័ព្ទលេខ:០១២ ៤៨១ ៥៩៧ សារអេឡិចត្រូនិច: cambodia@chabdai.org Website:www.chabdai.org


Scanned with CamScanner